ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ២៩៣/១២-៣-២០០៧

**សាលដីកា**

លេខ១០៣«ង»/០៣-៦-២០០៩

**គោរពនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី០៩-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី០៣-៦-២០០៩ដែលមានសមាសភាពដូចតទៅៈ

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជំរះ</u>**

**លោក [redacted] ប្រធាន**

**លោកស្រី [redacted] ចៅក្រមប្រឹក្សា**

**លោក [redacted] ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក [redacted]**

**ក្រឡាបញ្ជី**

**លោកស្រី [redacted]**

ដើម្បីជំនុំជំរះបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ២៩៣/១២-៣-២០០៧ រវាងៈ

**-ជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] រិន ហៅ ពៅ(ដើមបណ្តឹងឧទ្ធរណ៍)** ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ កើត និង ទីលំនៅសព្វថ្ងៃភូមិដូង ឃុំកញ្ចាំ [redacted] ឪពុកឈ្មោះ [redacted](ស)ម្តាយឈ្មោះ [redacted](ស)ប្រពន្ធឈ្មោះ [redacted] មានកូន២នាក់ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ០៨(ប្រាំបី)ឆ្នាំ។

ត្រូវចោទពីបទ ប្លន់ ប្រព្រឹត្តនៅភូមិត្នោត ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង កាលពីថ្ងៃទី២៦-៧-២០០៣ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ដែលប្រកាសឲ្យប្រើដោយរាជក្រមនស/រកម/០១០២/០០៤ចុះថ្ងៃទី០៧-០១-២០០២។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៥-១២-២០០៦របស់ជនជាប់ចោទ ឈ្មោ[redacted]រិន មិនសុខចិត្តត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

**ឯដំណើររឿងមានដូចតទៅ៖**

តាមកំណត់ហេតុបណ្តឹងចុះថ្ងៃទី២៧-៧-២០០៣បានបញ្ជាក់ថា កាលពីថ្ងៃទី២៦-៧-២០០៣វេលាម៉ោង៥ល្ងាច មានជនល្មើសចំនួន៤នាក់ បានយកអាវុធភ្ជង់កូនរបស់ពួកខ្លួនយកក្របីអស់ចំនួន៤ក្បាល ដើរទៅទិសខាងត្បូង។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ៤១«ក»/២០-១០-២០០៦របស់តុលាការខេត្តព្រៃវែងសំរេចសេចក្តីដូចតទៅ៖

១-ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៨(ប្រាំបី)ឆ្នាំ បន្តពីសាលក្រមលេខ៧០គចុះថ្ងៃទី១៤-៩-២០០៦របស់តុលាការខេត្តព្រៃវែង លើឈ្មោះ[redacted]រិន ហៅ [redacted] រិន ហៅ ពៅ ភេទប្រុស អាយុ៣២ឆ្នាំជាតិខ្មែរ មុខរបរធ្វើស្រែ កើត និង ទីលំនៅសព្វថ្ងៃភូមិដូង ឃុំ [redacted] ឪពុកឈ្មោះ[redacted](ស)ម្តាយឈ្មោះ[redacted] (ស)ប្រពន្ធឈ្មោះ[redacted] មានកូន២នាក់ ទោសពីមុនជាប់ពន្ធនាគារ០៨(ប្រាំបី)ឆ្នាំ។

២-ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៨(ប្រាំបី)ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ថ្ងៃទី២៤-៤-២០០៦លើឈ្មោះ[redacted] ហាន ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី៦ របររកស៊ីធ្វើស្រែ កើតនៅភូមិអណ្តូងថ្ម ឃុំពានរោង ស្រុក និង ខេត្តព្រៃវែង ទីលំនៅសព្វថ្ងៃ[redacted] ស្រុកកំចាយមារ ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោ[redacted](រ) ប្រពន្ធឈ្មោ[redacted] មានកូន២នាក់ ទោសពីមុនជាប់ពន្ធនាគារពីបទទទួលផលចោរកម្ម។

៣-ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់០៨(ប្រាំបី)ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបានតាមដីកាចាប់ខ្លួនលេខ៦១ដច០៦ចុះថ្ងៃទី០៨-៦-២០០៦របស់តុលាការខេត្តព្រៃវែង លើឈ្មោ[redacted] ចិន្តា ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី៩ថ្មី របររកស៊ីធ្វើស្រែ កើតនៅភូមិតាមោ ឃុំព្រៃកអន្ទះ ស្រុកកំពង់លាវ ខេត្តព្រៃវែង ទីលំនៅសព្វថ្ងៃ [redacted] ស្រុកកំពង់លាវ ខេត្តព្រៃវែង ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ[redacted] ប្រពន្ធឈ្មោះ[redacted] មានកូន៣នាក់។

ទាំង៣នាក់ប្រព្រឹត្តបទ ប្លន់ នៅភូមិត្នោត ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង កាលពីថ្ងៃទី២៦-៧-២០០៣ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ដែលប្រកាសឲ្យប្រើដោយរាជក្រមនស/រកម/០១០២/០០៤ចុះថ្ងៃទី០៧-០១-២០០២។

៤-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]ន ហៅ [redacted]រិ ហៅ ពៅ ឈ្មោ[redacted] ហាន កំបាំងមុខជនជាប់ចោទឈ្មោះ[redacted] ចិន្តា និង ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងជនរងគ្រោះទាំងអស់ ទុកសិទ្ធិប្តឹងទាស់រយៈ

ពេល១៥ថ្ងៃ គិតពីថ្ងៃទទួលលិខិតជូនដំណឹងនេះ និង ទុកសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល២ខែ បន្ថែមទៀត ក្រោយពីផុតរយៈពេលប្តឹងទាស់។

**ថ្នាន់ឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៥-១២-២០០៦របស់ជនជាប់ចោទ ឈ្មោះ[redacted]រិន មិនសុខចិត្តត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

បានឃើញរបាយការណ៍របស់សាលាឧទ្ធរណ៍។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ចៅក្រមអានរបាយការណ៍របស់សាលាឧទ្ធរណ៍.

ក្រឡាបញ្ជីអានចំលើយជនជាប់ចោទឈ្មោះ[redacted]រិន.

ក្រឡាបញ្ជីអានចំលើយដើមបណ្តឹងរដ្ឋប្បវេណី និង ជាជនរងគ្រោះ.

តំណាងមហាអយ្យការសន្និដ្ឋានះមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted] រិន ហៅ [redacted]រិន ,ឈ្មោះ[redacted]ហាន,[redacted]ចន្ថា ពីបទប្លន់ នៅភូមិត្នោត ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង កាលពីថ្ងៃទី២៦-៧-២០០៣ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។សាលក្រមព្រហ្មទណ្ឌលេខ៤១«ក» /២០-១០-២០០៦របស់តុលាការខេត្តព្រៃវែង មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ សុំក្រុមប្រឹក្សាសំរេចតំកល់សាលក្រមនេះទុកជាបានការដដែល។

## សាលាឧទ្ធរណ៍

១-យល់ឃើញថាបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៥-១២-២០០៦របស់ជនជាប់ចោទឈ្មោះ [redacted] រិន ហៅ[redacted]រិនធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា១៧៨នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និង មាត្រា៦០៩ក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថាសាលាឧទ្ធរណ៍បានសុំទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសុំមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ[redacted] រិន នេះ តែគ្មានចំលើយតបទេ។ដោយរឿងក្តីនេះ កើតហេតុតាំងពីឆ្នាំ២០០៣ សាលាឧទ្ធរណ៍គប្បីលើករឿងនេះមកពិចារណា។

៣-យល់ឃើញថា ចំលើយរបស់ជនជាប់ចោទឈ្មោះ[redacted] រិន បានទទួលសារភាពថា កាលពីឆ្នាំ២០០៣ ខ្លួនបានធ្វើសកម្មភាពប្លន់ជាមួយគ្នីគ្នា មានឈ្មោះ[redacted]ហាន ជាអ្នកកាន់អាវុធAKកាត់ស្វាយ១ដើម ឈ្មោះ[redacted]ចិន្ថា កាន់អាវុធK៥៩មួយដើម, ឈ្មោះ[redacted] ថា (ស្លាប់)កាន់ព្រនង់ និង រូបខ្លួនកាន់ដងរែកបាក់។មុនពេលធ្វើសកម្មភាពបាននាំគ្នាទៅជួបជុំនៅភូមិពោធិ៍រៀង រួចនាំគ្នាដើរសំដៅទៅភូមិត្នោត អង្គុយក្នុងព្រៃល្បះ ក៏បានឃើញក្មេង១៣-៤នាក់ដែលកំពុងដេញក្របីមេ៨ក្បាលសំដៅទៅផ្ទះ។ក្មេងទាំងនោះក្រោយពីឃើញពួកខ្លួនក៏រត់អស់ ពួកខ្លួនក៏នាំគ្នាដឹកក្របីទាំងអស់នោះយកទៅចងទុកក្នុងដីព្រៃស្រែរបស់[redacted]ថា ហើយនាំគ្នាទៅដេកនៅផ្ទះរបស់ឈ្មោះ[redacted]ថា ស្ថិតនៅភូមិខ្សាំ។អាវុធ

AKជារបស់ឈ្មោះ [redacted] ឡាក់។ឃើញថា អំពើរបស់ឈ្មោះ [redacted] រិន ជាអំពើប្លន់ តាមមាត្រា ៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

៤-យល់ឃើញថា សាលក្រមព្រហ្មទណ្ឌលេខ៩១«ក»/២០-១០-២០០៦របស់តុលាការខេត្តព្រៃវែងសំរេចមានលក្ខណៈត្រឹមត្រូវតាមច្បាប់។សាលាឧទ្ធរណ៍គប្បីសំរេចតំកល់សាលក្រមនេះទុកជាបានការដដែល។

ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តី**

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៥-១២-២០០៦របស់ជនជាប់ចោទឈ្មោះ [redacted] រិន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ៩១«ក»/២០-១០-២០០៦របស់តុលាការខេត្តព្រៃវែងទុកជាបានការ។

៣-បន្តឃុំខ្លួនលើឈ្មោះ [redacted] រិន តាមមាត្រា៣៥៣ និង មាត្រា៣៩៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈនៅថ្ងៃទី០៣-៦-២០០៩កំបាំងមុខជនជាប់ចោទ ។

បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកំលាំងប្រដាប់អាវុធគ្រប់ដំណែង ជួយសហការ អនុវត្តសាលដីកានេះឲ្យបានសំរេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ ថ្ងៃទី ២៤ ខែ ០២ ឆ្នាំ២០១៤

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

**ក្រឡាបញ្ជី**

[redacted]